# របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៦ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. <u>ស្ថានភាពមន្ត្រីរាជការ</u>÷

ស្ថានភាពមន្ត្រីរាជការ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ២៨ នាក់ ស្រី ០២ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. <u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷

- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារ របស់រដ្ឋបាលសាលាខេត្តក្រចេះ នៅសាលប្រជុំសាលាខេត្តប្រចាំឆ្នាំ២០១៥ និងទិសដៅឆ្នាំ២០១៦
    - ប្រចាំខែមករា នៅថ្ងៃទី១៩/០១/២០១៦
    - ប្រចាំខែកុម្ភៈ នៅថ្ងៃទី១០/០២/២០១៦
    - ប្រចាំខែមីនា នៅថ្ងៃទី១០/០៣/២០១៦
- ចូលរួមវេទិកាសាធារណៈដើម្បីត្រួតពិនិត្យ និងការគាំទ្រអនុវត្តកម្មវិធីគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ មានចំនួន ១៤ លើក
- ចូលរួមពិធីបិទការប្រកួតបាលទាត់ ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ នៅពហុកីឡាដ្ឋានខេត្តក្រចេះ
- ចូលរួមប្រជុំស្តីពីការចុះសិក្សាស្រាវជ្រាវវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបើក និងបិទអង្គសន្និបាតបូកសរុប វាយតម្លៃការងារអប់រំឆ្នាំ ២០១៤-១៥ និងទិសដៅបន្ត ២០១៥-១៦ (បើកថ្ងៃ២១ ខែមករា ឆ្នាំ២០១៦ និងបិទថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នៅសាលមហោស្រពខេត្ត)
- ចូលរួមប្រជុំគណៈកម្មការនាយកមូលនិធិសមធម៌ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ មន្ទីរពេទ្យបង្អែកស្រុកឆ្លូង
- ចូលរួមប្រជុំគណៈកម្មការនាយកមូលនិធិសមធម៌ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ មន្ទីរសុខាភិបាលខេត្ត
- ចូលរួមកម្មវិធីទិវាស្រែបង្ហាញ របស់គម្រោងកសាងភាពធន់ទៅនឹងការបម្រែបម្រួលអាកាសធាតុ និងសន្តិសុខស្បៀងក្នុងសហគមន៍ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នៅភូមិឈើទាលភ្លោះ ឃុំកញ្ជរ ស្រុកឆ្លូង
- ចូលរួមប្រជុំក្រុមប្រឹក្សាខេត្តលើកទី២០ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ នៅសាលក្រុមប្រឹក្សា
- ចូលរួមសិក្ខាសាលាស្តីពីប្រព័ន្ធផលិតកម្មផលិតស្រា ស ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នៅស្នួនកុមារ

- ចូលរួមកម្មវិធីប្រកាសតំបន់វិនិច្ឆ័យនៃការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធជូនពលរដ្ឋ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ នៅវត្តចង្ក្រង់
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការគ្រប់គ្រងបញ្ជីវត្តមាន នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមពិធីក្រុងពាលីបើកការដ្ឋានសាងសង់ស្ពានបេតុងកំពង់រាំង ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ នៅគល់ស្ពានកំពង់រាំង
- ចូលរួមពិធីបើកការដ្ឋានសាងសង់ស្ពានបេតុង នៅកំពង់រាំង ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៦ស្រុកឆ្លូង
- ចូលរួមសម្ពោធសាលាបឋមសិក្សាប្រម៉ា ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦ នៅភូមិប្រម៉ា
- ចូលរួមពិធីបញ្ចុះផ្ទាំងសិលាភ្នំសុពិណកាឡី ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៦ នៅវត្តភ្នំសុពិណកាឡី
- ចូលរួមប្រជុំស្តីពីការកែលម្អរស្តង់ដារឯកសារដេញថ្លៃ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលាខេត្តក្រចេះ
- ចូលរួមប្រជុំបើក និងវាយតម្លៃឯកសារដេញថ្លៃផ្លូវ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ នៅភ្នំពេញ
- ចូលរួមប្រជុំណែនាំដល់ប្រជាពលរដ្ឋមុខសញ្ញាអ្នកទទួលដី ៩៩៨ គ្រួសារ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦ នៅស្រុកឆ្លូង
- ចុះពិនិត្យ និងធ្វើការណែនាំដល់ប្រជាពលរដ្ឋក្រុមអនាធិបតេយ្យទន្រ្ទានដី ៩៩៨ គ្រួសារ ថ្ងៃទី១៧ ដល់១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅភូមិប្រម៉ា
- ចូលរួមប្រជុំពិភាក្សា ពីការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលាខេត្ត
- ចូលរួមប្រជុំពិនិត្យ និងកែសម្រួលលទ្ធផលរបាយការណ៍វេទិកាសាធារណៈឆ្នាំ២០១៥ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលាខេត្ត
- ចូលរួមកិច្ចប្រជុំសាមញ្ញកិច្ចការស្ត្រី ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សា
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី២១ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចូលរួមប្រជុំប្រចាំឆ្នាំ២០១៥-១៦ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ នៅខេត្តព្រះសីហនុ
- ចូលរួមជាភ្ញៀវកិត្តយស ក្នុងកម្មវិធីសម្ពោធសមិទ្ធិផលនានា ក្នុងវត្តដារថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦
- ចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមា នៅវត្តចន្ទរង្សី ឃុំជ្រោយបន្ទាយ ថ្ងៃទី២០ខែកុម្ភៈ ឆ្នាំ២០១៦
- ចូលរួមប្រជុំស្តីពីការធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិកើនថយ ឆ្នាំ២០១៥ កំណត់តម្លៃដី អាគារ វិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ព្រមទាំងធ្វើបច្ចុប្បន្នភាពស្ថិតិអង្គភាពប្រើប្រាស់ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាសប្រជុំសាលាខេត្តក្រចេះ

- ចូលរួមប្រជុំវាយតម្លៃប្រគល់ និងទទួលបញ្ចប់សុពលភាពការងារថែរទាំ ជួសជុលអណ្តូងស្នប់ ស្រុកស្នួល និងស្រុកចិត្របុរី នៅសាលប្រជុំសាលាខេត្តក្រចេះ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦
- ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីសម្ពោធអាគារសិក្សាថ្មី នៅវិទ្យាល័យថ្មគ្រែ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦
- ចូលរួមប្រជុំពិភាក្សា ស្តីពីការរៀបចំ និងបង្កើតសមាគមមនុស្សចាស់តាមឃុំគោលដៅ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំមន្ទីរសង្គមកិច្ច
- ចូលរួមសិក្ខាសាលាស្តីពី ការអភិវឌ្ឍន៍បៃតង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលប្រជុំសណ្ឋាគារ ហ៊ារ ប៊ុន្នី ខេត្តក្រចេះ
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីទិវាអន្តរជាតិ៨មីនា នៅថ្ងៃទី១១ មីនា ឆ្នាំ២០១៦ នៅសាលមហោស្រព ខេត្តក្រចេះ
- ចូលរួមប្រជុំផ្សព្វផ្សាយ អនុក្រឹត្យលេខ២៦ អន.ក្រ.បក ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីកិច្ចសន្យា ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំមន្ទីរសង្គមកិច្ច ខេត្តក្រចេះ
- ចូលរួមពិធី ទិវាវប្បធម៌ជាតិ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ នៅសាលមហោស្រពខេត្តក្រចេះ
- ចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្តសិរីវឌ្ឍនារាម នៅឃុំវឌ្ឍនះ ស្រុកសំបូរ ថ្ងៃទី១៥ មីនា ឆ្នាំ២០១៦
- ចូលរួមពិធីបុណ្យ បញ្ចុះខណ្ឌសីមាវត្តកោះច្បារ ឃុំកោះខ្ញែរ ស្រុកសំបូរ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦
- ចូលរួមប្រជុំក្រុមប្រឹក្សាខេត្ត លើកទី២២ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ ។

3. **សកម្មភាពតាមការិយាល័យ÷**

3.1. **ការិយាល័យរដ្ឋបាល និងបុគ្គលិក÷**

ក. ផ្នែកការងារលិខិតចូល ÷ សរុបចំនួន ១៣៦លេខ ក្នុងនោះមានៈ

- លិខិតចូលពីអង្គភាពនានាក្រៅមន្ទីរ ចំនួន ១១៨លេខ
- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ១៨លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ១៥៦ លេខ ក្នុងនោះមាន÷

- លិខិតទៅបណ្តាអង្គភាពនានាក្រៅមន្ទីរ ចំនួន ៤៦លេខ
- លិខិតពាក់ពន្ធ័ស្ថានភាពមន្ត្រីរាការ ចំនួន ៩៦ លេខ
- លិខិតចេញទូទៅ (លិខិតអញ្ជើញ និងជូនដំណឹង) ចំនួន០៦ លេខ
- លិខិតចេញទៅបណ្តាអង្គភាពនានាក្រោមឱវាទ ចំនួន០៨ លេខ

គ. <u>ផ្នែកបញ្ជីវត្ថុមាន</u>÷ ពិនិត្យការចុះបញ្ជីវត្ថុមានជាប្រចាំថ្ងៃ ។

3.2. <u>**ការិយាល័យផ្លូវលំជនបទ÷**</u>

- ក្រុមការងារនាយកដ្ឋានផ្លូវលំជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចុះសិក្សាផ្លូវចំនួន ០១ ខ្សែ ពីភូមិខ្សាច់វែង ទៅភូមិដារជ្រៃ ប្រវែង ១៦ ០០០ម៉ែត្រ ដែលស្ថិតនៅឃុំកញ្ជរ ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល
- ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទចុះសិក្សាផ្លូវ០១ខ្សែ ពីភូមិអូរឬស្សី២ទៅភូមិបន្ទាយ ប្រវែង ៦១០០ ម៉ែត្រ ដែលស្ថិតនៅសង្កាត់អូរឬស្សី ក្រុងក្រចេះ និងឃុំគោលាប់ ស្រុកចិត្តបុរី
- ចុះស្រង់ទិន្នន័យផ្លូវជនបទតាមប្រព័ន្ធ GPS សម្រាប់រៀបចំផែនទីក្នុងខេត្ត បានចំនួន ០៧ខ្សែ ៦០ ២០០ម៉ែត្រ ដែលិ្ថតនៅឃុំកញ្ជរ ស្រុកឆ្លូង ឃុំបុសលាវ ស្រុកចិត្របុរី ឃុំស្វាយជ្រះ ស្រុកស្នួល
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវតាមប្រព័ន្ធ PGS បាន ១៤ ខ្សែ ប្រវែង ២០៦ ២០០ ម៉ែត្រ ដែលស្ថិតនៅឃុំព្រែកប្រសព្វ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- បញ្ជាក់បច្ចេកទេសមូលនីធិឃុំសង្កាត់ របស់សាលាខេត្ត បានចំនួន ០២ គម្រោង
- ចុះសិក្សាស្ពានអំពក ប្រវែង ៣៤ ម៉ែត្រ តាមសំណើរបស់ប្រជាពលរដ្ឋក្នុងវេទិកាសាធារណៈ ស្ថិតនៅឃុំស្រែជិះ ស្រុកសំបូរ
- ចុះសិក្សាផ្លូវចំនួន០២ខ្សែ ប្រវែង១០ ១៣៦ម៉ែត្រ តាមសំណើរបស់ប្រជាពលរដ្ឋ ក្នុងវេទិកាសាធារណៈ ស្ថិតនៅឃុំស្នួល និងឃុំ២ធ្នូ ស្រុកស្នួល
- ចូលរួមពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាពផ្លូវជាមួយគណៈកម្មការអន្តរក្រសួង ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន០២ខ្សែ ប្រវែង១២០០០ម៉ែត្រ និងលូ ០៤កន្លែង ស្ថិតនៅឃុំឃ្សឹម ឃុំស្នួល ស្រុកស្នួល ។

3.3. <u>**ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷**</u>

- ចុះជួសជុលអណ្តូងស្នប់អាហ្វ្រីដេស បានចំនួន ០៥ អណ្តូង ស្រុកស្នួល ០៤ អណ្តូង និងក្រុងក្រចេះ ០១ អណ្តូងក្នុងនោះមាន÷
  - o ឃុំស្វាយជ្រះ ០៤អណ្តូង នៅភូមិរំពុក ០២ អណ្តូង និងភូមិតាពុំ ០២ អណ្តូង
  - o ក្រុងក្រចេះចំនួន ០១ អណ្តូង នៅសង្កាត់ក្រគរ ភូមិទួលមនោរម្យ ។
- ចុះស្រង់ទិន្នន័យធ្វើបច្ចុប្បន្នភាពអណ្តូងស្នប់ អណ្តូងលូ និងស្រះសហគមន៍ ដែលរីងស្ងួតដោយសារកត្តាប្រែប្រួលនៃអាកាសធាតុ បាន ០៥ ស្រុក មានស្រុកចិត្របុរី ស្រុកសំបូរ ស្រុកព្រែកប្រសព្វ ស្រុកស្នួល និងស្រុកឆ្លូង ក្នុងនោះអណ្តូងស្នប់បានចំនួន ៣១៧ អណ្តូងលូបាន ៧៥១ ស្រះសហគមន៍២៩៨ ។

3.4. <u>**ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷**</u> (គ្មានសកម្មភាព)

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍÷</u>**

សហការជាមួយអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ ដឹកនាំគ.អ.ភ ក្រុមប្រឹក្សាឃុំ និងតំណាងស្រុកឆ្លូងទៅធ្វើទស្សនកិច្ចសិក្សានៅខេត្តកំពត និងកំពង់ស្ពឺ ដែលមានអ្នកចូលរួមសរុប ៤៨ នាក់ ក្នុងនោះស្ត្រីមានចំនួន ១៤ នាក់។

3.6. **<u>ការិយាល័យជនជាតិដើមភាគតិច÷</u>** (គ្មានសកម្មភាព)

3.7. **<u>ការិយាល័យថែទាំសុខភាពជនបទ÷</u>** (គ្មានសកម្មភាព)

3.8. **<u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ÷</u>** មានចំនួន ០៣ លើក ។

4. **<u>ទិសដៅបន្ត÷</u>**

- ចុះស្រង់ទិន្នន័យផ្លូវ និងធ្វើបច្ចុប្បន្នភាពផ្លូវស្រុកព្រែកប្រសព្វ ស្រុកសំបូរ ស្រុកស្នួល និងស្រុកចិត្របុរី ។
- ជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវឃុំកំពងដំរី ឃុំអូរគ្រៀង ប្រវែង៥១គ.ម ស្រុកសំបូរ និងស្រុកឆ្លូង ។
- ជួសជុលថែទាំជាលក្ខណៈខួបផ្លូវឃុំព្រែកប្រសព្វ ឃុំកំពង់គរ ឃុំតាម៉ៅ និងឃុំកញ្ជរ ប្រវែង ៣៧.៧០គ.ម ស្រុកព្រែកប្រសព្វ និងស្រុកឆ្លូង ។
- ជួសជុលអណ្តូងស្នប់ចំនួន ៧០ អណ្តូង នៅស្រុកស្នួល ស្រុកចិត្របុរី និងស្រុកសំបូរ ។
- ចុះតាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាពគ.អ.ភ ក្នុងឃុំបឹគី ឃុំស្វាយជ្រះ ឃុំឃ្សឹម និងឃុំស្នួល នៅស្រុកស្នួល ។

**ប្រធានមន្ទីរ**